**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៤៨០៤ ព.ណ.ត.ក

ថ្ងៃសុក្រ ១០កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់សហគ្រាស ផលិតករ សេវាករ ពាណិជ្ជករ និងសាធារណជនទូទៅឲ្យបានជ្រាបថា៖ រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ សហការជាមួយមជ្ឈមណ្ឌលអាស៊ាន-កូរ៉េ និងភ្នាក់ងារជំរុញពាណិជ្ជកម្ម និងវិនិយោគកូរ៉េ នឹងរៀបចំពិព័រណ៍ធុរកិច្ច អាស៊ាន-កូរ៉េ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៣-២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ។

ដំណឹងនេះចាត់ទុកដូចជាការអញ្ជើញ ឧកញ៉ា លោក លោកស្រីដែលជាម្ចាស់សហគ្រាស ផលិតករ ពាណិជ្ជករ សេវាករ និងម្ចាស់ក្រុមហ៊ុនវិនិយោគ ដែលកំពុងធ្វើធុរកិច្ចលើវិស័យកសិ-ឧស្សាហកម្ម វិស័យសំណង់ សេវាកម្មដឹកជញ្ជូន និងឡូជីស្ទីក បច្ចេកវិទ្យា និងគម្រោងអភិវឌ្ឍន៍សហគមន៍ ដែលមានចំណាប់អារម្មណ៍ និងបំណងទៅចូលរួមផ្សព្វផ្សាយពីផលិតផល ឬសេវាកម្មរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្ម ក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ សូមមកទាក់ទង និងបំពេញបែបបទនៅនាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវពាក្យស្នើសុំចូលរួម និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ចាប់ពីថ្ងៃជូនដំណឹងនេះរហូត ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩។

គណៈកម្មការរៀបចំពិព័រណ៍ និងរ៉ាប់រងការចំណាយក្នុងការចូលរួមជូនក្រុមហ៊ុនចំនួន ៥ (១នាក់ ក្នុងមួយក្រុមហ៊ុន) ដើម្បីទៅចូលរួម។ សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទី២ នៃអគារទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍ លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១២ ៧០៣ ៣៩៣ / ០៩៧ ៥៦៦ ៦៩៩៩/ ០១២ ៩៦០ ២០០/០១២ ៦០០ ៧៧៨
អាសយដ្ឋានអ៊ីម៉ែល៖cheaputhea@yahoo.com/veasna_mao@yahoo.com/ sopheap.sok56789@gmail.com

សូមអរគុណ!

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N° 28.04.MOC D.E.A....

Phnom Penh, 23 July 2019

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all producers, traders, service providers and entrepreneurs that The Korean Government in collaboration with ASEAN-Korean Center and Korea Trade-Investment Promotion Agency is going to organize "ASEAN-KOREAN Business Expo which will be held from 23rd to 27th November 2019 in Busan, Republic of Korea.

In this regard, the Ministry of Commerce would like to invite all interested entrepreneurs, producers, traders, service providers and investment companies of which their business activities related to agro-processing industries, construction, logistic, technology and rural development community project who wish to showcase their products, service or/and looking for business partnership, please submit their application form to Department of Exhibition Affairs, General Directorate of Trade Promotion of the Ministry of Commerce no later than 26 July 2019.

Please noted that the organizing committee will shoulder the expenses for 5 qualify Cambodian Companies (1 person for one company) for participation with the above Expo. For further information, please contact:

Department of Exhibition Affairs, General Directorate of Trade Promotion,
The Ministry of Commerce:
Lot No. 19-61, Russian Federation Blvd,
Phum Toek Thla, Sangkat Toek Thla,
Khan Sen Sok, Phnom Penh,

Tel: 012 703 393/ 097 566 6999/ 017 960 200 / 012 600 778

E-mail: sopheap.sok56789@gmail.com / cheaputhea@yahoo.com / veasna_mao@yahoo.com

THANK YOU!